ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាជំនុំរដ្ឋប្បវេណី

-------------

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៦២

ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

សាលដីកា

លេខ : ១៧០

ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៨

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចខាងក្រោម :

១.ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២.លោក វ៉ែន ស៊ិន ជាចៅក្រម

៣.លោក ទៀល ម៉ួន ជាចៅក្រម

៤.លោក ស៊ិន ឌឹម ជាចៅក្រម

៥.លោក ជីវ កេង ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

កញ្ញា ភួង ចន្ថា

តំណាងមហាអយ្យការ

លោក ដួន ស៊ិនទេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៦៧៥ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦០ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ នូ ទេឡុង អាយុ ៥៨ ឆ្នាំ ជាតិខ្មែរ របរកសិ លក់ដូរ មានទីលំនៅភូមិទួលតាចាន់ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ជាវ គង់ "ស" ម្តាយឈ្មោះ ម៉ាង រឿង "ស" ប្តីឈ្មោះ ដួង សម្បត្តិ មានកូន ១ នាក់ ។

និងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ជុំ វុធារ៉ា អាយុ ២៩ ឆ្នាំ ជាតិខ្មែរ របរកសិ នៅផ្ទះ មានទីលំនៅភូមិទួលតាចាន់ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ជុំ ភារីណុទ្ធ "រស់" ម្តាយឈ្មោះ នូ សារ៉ុន "ស" ប្តីឈ្មោះ ដារ៉ាន់ សុជាតិ មានកូន ០៤នាក់ ។

កម្មវត្ថុ : បណ្តឹងទាមទារសិទ្ធិកាន់កាប់ដី និងបដិសេធប័ណ្ណកម្មសិទ្ធិដី

៣ :

បានឃើញបណ្ដឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៥៨ របស់ឈ្មោះ នូ ទេឡុង ប្ដឹងមិនសុខចិត្ត និងសេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ-១៩៥៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០៣.៧.១៩៥៦ របស់ឈ្មោះ ជុំ រ៉ូយ៉ារ៉ា ប្ដឹងទាម-ទារដីតាមបណ្ដាំពីឈ្មោះ នូ ទេឡុង ដោយសំអាងហេតុថា ដីដែលខ្លួនរស់នៅសព្វថ្ងៃជាដីរបស់តា-ផាន់ គង់ និងយាយមាយ ទេវ៉ឹង បានចែកអោយខ្លួនតាំងពីឆ្នាំ ១៩៤៦ ហើយខ្លួនក៏សង់ផ្ទះនៅលើដីនោះរហូតមក ឯឈ្មោះ នូ ទេឡុង កាលនោះរស់នៅឯខេត្តសៀមរាប ទើបតែឆ្នាំ ១៩៥៥ បានឈ្មោះនេះមកនៅលើដីជាចំណែករបស់គាត់ជាប់ដីរបស់ខ្លួន ។ នៅឆ្នាំ ១៩៥២ ឈ្មោះនូ ទេឡុង បានធ្វើប័ណ្ណកម្មសិទ្ធិ ដោយរួមជាមួយដីរបស់ខ្លួន ដោយបាននិយាយថា គាត់នៅតែប្រគល់ដីខ្លួនតាមបណ្ដាំនេះដែល ។ សព្វថ្ងៃនេះគាត់ដើរនិយាយថា បើថ្ងៃក្រោយយាយ មាយ ទេវ៉ឹង ស្លាប់គាត់និងដេញខ្លួនចេញពីដីនេះ ព្រោះប្លង់នៅលើគាត់ហើយ លោកយាយមាយ ទេវ៉ឹង ក៏មិនចែកដីអោយខ្លួនដែរ ។

តាមពាក្យបណ្ដឹងតបចុះថ្ងៃទី ២៥.៧.៥៦ របស់ឈ្មោះ នូ ទេឡុង ប្ដឹងសុំអោយឈ្មោះ ផាន់ សុផាត និង ជុំ រ៉ូយ៉ារ៉ា រុះរើផ្ទះចេញពីដីខ្លួន ដោយសំអាងហេតុថា ដីនេះជាកម្មសិទ្ធិរបស់ខ្លួនដែលឪពុកខ្លួនបែងចែកអោយខ្លួននៅឆ្នាំ ១៩៥០ ។ នៅឆ្នាំ ១៩៥១ ឈ្មោះ-ជុំ រ៉ូយ៉ារ៉ា បានមកខ្ចីដីខ្លួនធ្វើផ្ទះនៅ លុះដល់ឆ្នាំ ១៩៥៣ ឈ្មោះ ជុំ រ៉ូយ៉ារ៉ា បានរុះរើផ្ទះចេញហើយសង់ផ្ទះធំជាងមុនទៀត ពេលនោះខ្លួនពុំបានឃាត់ទេ ព្រោះខ្លួននៅខេត្តសៀមរាប ពេលខ្លួនមកដល់ឈ្មោះនេះធ្វើផ្ទះរួចហើយឈ្មោះនេះសុំរង់ចាំខ្លួនធ្វើផ្ទះនៅសិនទៅ ពេលមានរុះរើ-ចេញអោយដីមកខ្លួនវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១១ "ត" ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ១៩៥២ របស់តុលាការខេត្តកណ្ដាលដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១.ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៣.៧.៥៦ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២.ទទួលពាក្យបណ្ដឹងតបត្រឡប់ចុះថ្ងៃទី ២៥.៧.៥៦ របស់ចុងចំលើយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣.បដិសេធប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G2-១៦៨១ ចុះថ្ងៃទី០៥.០៥.៥៣ ដែលចុះឈ្មោះ នូ ទេឡុង ជាកម្មសិទ្ធិចោលជាអាសារបង់តាមសំណូមពររបស់លោកយាយមាយទេវ៉ឹងជាម្ចាស់ទ្រព្យ ។

៤.ប្រគល់សិទ្ធិកាន់កាប់ដីទំហំក្បាល ១៣ម ក្នុងដី ១៦ម បណ្ដោយដី ១៥ ៥ម ដែលមានព្រំប្រទល់ខាងកើតជាប់ផ្លូវជាតិលេខ ១ ខាងត្បូងទល់នឹងព្រំដី នូ ចិន្ដា ខាងលិចទល់ នូ ទេឡុង

ៗ,

និងខាងកើតទល់នឹងព្រំដីឈ្មោះ ប៉ែន វិមាន អោយទៅឈ្មោះនាងជុំ រ៉ូយ៉ារ៉ា គ្រប់គ្រងជា កម្មសិទ្ធិតទៅ ។

៥.នាងជុំ រ៉ូយ៉ារ៉ា ត្រូវចុះបញ្ជីអចលនៈវត្ថុនៅការិយាល័យសុរិយោដីខេត្ត ។

៦.បង្គាប់អោយឈ្មោះ នូ ទៀង បង់ប្រាក់ប្រដាប់ក្ដី សរុប ៧.០០០៛ ក្នុងនោះពន្ធប្ដឹង និង ពន្ធចុះបញ្ជីក្ដី ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ និងពន្ធលើការ ស៊ើបអង្កេត ៥.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ តែអោយចុងចម្លើយសងទៅដើមចោទ វិញ និងបង្គាប់អោយឈ្មោះ នូ ទៀង បង់ពន្ធសមាមាត្រមួយភាគរយ លើតំលៃដីសរុប ៣,៦លាន រៀល ស្មើនឹង ៣៦.០០០រៀល ក្នុងនោះរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ ស្មើនឹង (៣៦.០០០៛ គុណ ២០)/១០០ : ៧.២០០៛ និងបង់ចូលថវិកាជាតិ ៨០ ភាគរយស្មើនឹង (៣៦.០០០៛ គុណ ៨០)/១០០ : ២៨.០០០៛ ។

៧.សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ នៅចំពោះមុខគូក្ដី ។ បើកផ្លូវ ឧទ្ធរណ៍រយៈពេល ២ ខែ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៨៧ របស់ឈ្មោះ នូ ទៀង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៣៥ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ- ១៩៨៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ និងសេចក្ដីសំរេចដូចតទៅ :

១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២១.០២.៨៧ របស់ឈ្មោះ នូ ទៀង ទុក ត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាល់ខុស នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០១ "គ" ចុះថ្ងៃទី ០៣.០១.១៩៨៧ របស់តុលាការខេត្ត កណ្ដាល ទុកជាបានការ ។ តែកែប្រែចំណុចទី ៤ ដូចតទៅ :

-បែងចែកដីទំនាស់ដែលស្ថិតនៅភូមិទួលតាចាន់ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល ជាពីរចំណែកស្មើគ្នា ពីមុខទៅក្រោយ ដោយឈ្មោះ ជុំ រ៉ូយ៉ារ៉ា ត្រូវទទួលបានផ្នែកខាង កើត ឈ្មោះ នូ ទៀង ត្រូវទទួលបាននូវផ្នែកខាងលិច ។

៣.សំរេចកាត់យកប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ២.៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិប ប្រាក់ ៤៥០ រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០ រៀល ។

៤.សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី ។ សំរេចបើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៤ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៨ របស់ឈ្មោះ នូ ទៀង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

។/.

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖

ព្រោះពីបានពិនិត្យមើលសាលដីការដ្ឋប្បវេណីលេខ ២៧៥ ចុះថ្ងៃទី ១៨.១១.៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

ឈ្មោះ នួ ទៀង បានទទួលលិខិតបង្គាប់អោយផ្ញើសារណារបស់តុលាការកំពូលរួចហើយ ប៉ុន្តែពុំបានផ្ញើសារណាជូនមកតុលាការតាមការកំណត់ទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ជុំ វ៉ៃយ៉ារ៉ា ជាចុងចោទ និងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះរូបនេះឆ្លើយថា សូមអោយលោកតុលាការជួយរកយុត្តិធម៌អោយខ្លួនផង ព្រោះដីនេះ យាយខ្លួនចែកអោយខ្លួនតាំងពីឆ្នាំ ១៩៨២ ។ ហើយលោកស្រី នួ ទៀង គាត់រស់នៅឯខេត្តសៀមរាប ទេ ហើយគាត់ទើបមករស់នៅលើដីនេះនៅឆ្នាំ ១៩៩៤ នេះទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី ជុំ វ៉ៃយ៉ារ៉ា
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

ឃើញថា បណ្តឹងសាទុក្ខលេខ ១៤ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៨ របស់អ្នកស្រី នួ ទៀង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

ឃើញថា លោកតា ផាវ គង់ និង លោកយាយ មាឃ ទៀង បានបែងចែកដីតាក់ក្តាលអោយទៅអ្នកស្រី នួ ទៀង រួចហើយ រីឯដីតាក់ក្តាលទៀតដែលជាដីចំណាស់នេះ គាត់បានបែងចែកអោយទៅអ្នកស្រី ជុំ វ៉ៃយ៉ារ៉ា ដូចេ្នះអ្នកស្រី ជុំ វ៉ៃយ៉ារ៉ា មានសិទ្ធិលើដីនេះ តាមមាត្រា ១៤៩ នៃច្បាប់ភូមិបាល និងតាមមាត្រា ៥ នៃអនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ២២.០៤.៨៩ ។

ឃើញថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ G2.១២៨១ ចុះថ្ងៃទី ០៥.៤.៩៣ ដែលរួមមានទាំងចំណែកដីចំណាស់នៅក្នុងនោះផង គឺ ធ្វើឡើងតាមសំណូមពររបស់ម្ចាស់ដីដើម ប៉ុន្តែនៅពេលដែលមានចំណាស់ម្ចាស់ដីបានសំណូមពរអោយបំបែកប័ណ្ណកម្មសិទ្ធិដីនេះជាពីរ តាមចំណែកដីនិមួយៗ ដែលម្ចាស់ដីបានប្រគល់អោយ ដូចេ្នះអ្នកស្រី នួ ទៀង ពុំអាចឡើងជាកម្មសិទ្ធិករលើដីចំណាស់នេះ តាមអំណាចប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G2. ១២៨១ ចុះថ្ងៃទី០៥.៤.៩៣ នេះឡើយ ។

យល់ឃើញថា អ្នកស្រី នូ ទៀង បានទទួលលិខិតបង្គាប់អោយធ្វើសារណារួចហើយ ប៉ុន្តែអ្នកស្រីពុំបានធ្វើសារណាជូនមកតុលាការកំពូល តាមការកំណត់ទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៧៥ ចុះថ្ងៃទី ១៨.១១.៨៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

ដោយហេតុនេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខអ្នកស្រី ជុំ វ៉ូយ៉ាវ៉ា កំបាំងមុខអ្នកស្រី នូ ទៀង ប៉ុន្តែចាត់ទុកជាចំពោះមុខ ៖

១.ទទួលបណ្តឹងសាទុក្ខលេខ ១៤ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៨៨ របស់អ្នកស្រី នូ ទៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២.តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៧៥ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣.រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី នូ ទៀង បានបង់រួចហើយគឺ ៖

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

បង្គាប់អោយអ្នកស្រី នូ ទៀង បង់ពន្ធសមាមាត្រតាមការកំណត់ របស់តុលាការខេត្តកណ្តាល ។

៤.សាលដីកានេះ ប្រកាសនៅសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៨៩ ។